សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា

Cambodian Journalists Alliance Association

# របាយការណ៍ស្តីពី
# ការឃ្លាំមើលស្ថានភាពសារព័ត៌មាននៅកម្ពុជា ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣

ខែមករា-មីនា ឆ្នាំ២០២៣ | ចេញផ្សាយ ០៤



របាយការណ៍ប្រចាំត្រីមាសដែលចេញផ្សាយដោយខមបូចាគឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការឃ្លាំមើលនិងការតស៊ូមតិដើម្បីសេរីភាពសារព័ត៌មាននៅកម្ពុជា។របាយការណ៍នេះមានបញ្ចូលនូវការសង្ខេបខ្លីៗអំពីឧប្បត្តិហេតុព្រមទាំងបច្ចុប្បន្នភាពដែលទាក់ទងនឹងសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិរបស់អ្នកសារព័ត៌មានចាប់ពី ខែមករារហូតដល់ខែមីនា ឆ្នាំ២០២៣។

ការវិវឌ្ឍគួរឲ្យចាប់អារម្មណ៍មួយដែលយើងឃ្លាំមើលក្នុងត្រីមាសនេះ គឺការសម្រេចចិត្តរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងការបិទវិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) ដែលជាប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមួយក្នុងប្រទេស។ក្រៅពីវិទ្យុសំឡេងប្រជាធិបតេយ្យមានសារព័ត៌មានអនឡាញយ៉ាងហោចណាស់ ៤អង្គភាពផ្សេងទៀតត្រូវបានក្រសួងព័ត៌មានដកហូតអាជ្ញាបណ្ណក្នុងត្រីមាសនេះ។

ដោយពិនិត្យទៅលើសុវត្ថិភាពអ្នកសារព័ត៌មានពីទិដ្ឋភាពបីគឺ ទិដ្ឋភាពផ្លូវកាយ អនឡាញ និងសុវត្ថិភាពផ្លូវច្បាប់ ខេមបូចា បានកត់ត្រាករណីយីយាមកលើអ្នកសារព័ត៌មានយ៉ាងហោចណាស់៨ករណី រួមទាំងករណីបៀតបៀនផ្លូវភេទលើអ្នកយកព័ត៌មានវីអូឌី ជាស្ត្រី និងការរករឿងអ្នកសារព័ត៌មាន VOD បន្ទាប់ពីវិទ្យុរបស់ពួកគេត្រូវបានបិទ។

នៅក្នុងរបាយការណ៍នេះ យើងក៏បានចងក្រងបច្ចុប្បន្នភាពឧប្បត្តិហេតុសំខាន់ៗមួយចំនួនទាក់ទងនឹងបរិយាកាសប្រព័ន្ធផ្សព្វផ្សាយនៅក្នុងត្រីមាសនេះដែរ។

**ទាំងអស់គ្នាដើម្បីសេរីភាពសារព័ត៌មាន**

# ឧប្បត្តិហេតុដែលបានរាយការណ៍នៅក្នុងត្រីមាសនេះ


១ ក្រសួងព័ត៌មានបានដកអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួន៣អង្គភាព បន្ទាប់ពីបានរាយការណ៍ព័ត៌មានពីមន្ត្រីជាន់ខ្ពស់ដែលមានការជាប់ពាក់ព័ន្ធនឹងការបន្លំលួចដីធ្លី។ 6

២ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បិទប្រព័ន្ធផ្សព្វផ្សាយឯករាជ្យវីអូឌី ។ 8

៣ ក្រោយការបិទវីអូឌី មានការបង្កជម្លោះរករឿងអ្នកសារព័ត៌មាន។ 11

៤ អ្នកកាសែតអនឡាញម្នាក់ត្រូវបានចាប់ខ្លួន បន្ទាប់ពីថតរូបការរត់ពន្ធបារី។ 14

៥ អ្នកសារព័ត៌មានតាមអនឡាញម្នាក់ រងការយាយីផ្នែករាងកាយពីម្ចាស់អាជីវកម្មបូមខ្សាច់។ 15

៦ អ្នកសារព័ត៌មានអនឡាញពីរនាក់បានត្រូវអ្នកលេងល្បែងកញ្ឆក់យកទូរស័ព្ទ។ 15

៧ អាជ្ញាបណ្ណគេហទំព័រមួយត្រូវបានដកហូត បន្ទាប់ពី'បានបំពានក្រមសីលធម៌យ៉ាងធ្ងន់ធ្ងរ។ 16

៨ អ្នកសារព័ត៌មានពលរដ្ឋម្នាក់ត្រូវចាប់ខ្លួន និងបង្ខំឲ្យលុបរូបថត។ 18

# បច្ចុប្បន្នភាពឧប្បត្តិហេតុសំខាន់ៗ


I ស្ថានទូតនានា និងអង្គការសង្គមស៊ីវិលព្រមានថា ការបិទវីអូឌី ធ្វើឲ្យខូចខាតដល់សេរីភាពសារព័ត៌មាន។ 19

II អ្នកសារព័ត៌មានប្រចាំខេត្តឧត្តរមានជ័យទាំងអស់បញ្ជូនឲ្យរាយការណ៍ទៅសាលាខេត្ត។ 21

III លោកនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងធ្វើចប់រួចរាល់នៅឆ្នាំ២០២៥។ 21

# សេចក្តីសង្ខេប នៃឧប្បត្តិហេតុនៃការយាយីលើអ្នកសារព័ត៌មាន ដែលកត់ត្រាចាប់ពីថ្ងៃទី ១ ខែមករា ដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២៣

| ទិដ្ឋភាពសុវត្ថិភាព | ប្រភេទនៃការយាយី | ចំនួននៃអង្គភាពសារព័ត៌មាន/ អ្នកកាសែតដែលរងការប៉ះពាល់ |
|---|---|---|
| *សុវត្ថិភាពផ្នែករាងកាយ* | *ការវាយប្រហារលើឧបករណ៍និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនការយាយីលើរាងកាយ ការបំភិតបំភ័យដោយពាក្យសំដី* | *មានអ្នកកាសែត ៥នាក់ ក្នុងនោះក៏មានអ្នកកាសែតពលរដ្ឋម្នាក់ដែរ* |
| *សុវត្ថិភាពតាមអនឡាញ* | *ការបៀតបៀនផ្លូវភេទតាមអនឡាញ ការគំរាមកំហែងតាមអនឡាញ* | *អ្នកយកព័ត៌មានស្រីម្នាក់ និងអ្នកយកព័ត៌មានប្រុសម្នាក់របស់* VOD |
| *សុវត្ថិភាពផ្នែកច្បាប់* | *ការបិទ ឬផ្អាកដំណើរការប្រព័ន្ធផ្សព្វផ្សាយដោយអាជ្ញាធរ* | *អាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ ៥អង្គភាព ត្រូវបានដកហូត* |

## ១. ក្រសួងព័ត៌មានបានដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ៣អង្គភាព បន្ទាប់ពីរាយការណ៍ពីមន្ត្រីជាន់ខ្ពស់ម្នាក់ដែលមានជាប់ពាក់ព័ន្ធនឹងការបន្លំយកដីធ្លី។

*ក្រសួងព័ត៌មានបានដកហូតអាជ្ញាបណ្ណរបស់ប្រព័ន្ធផ្សព្វផ្សាយ៣អង្គភាពកាលពីខែមីនាបន្ទាប់ពីអង្គភាពទាំងនេះបានចេញផ្សាយព័ត៌មានលាតត្រដាងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ម្នាក់ ដែលជាប់ពាក់ព័ន្ធនឹងការលួចបន្លំយកដីធ្លី។*

*ក្រសួងបញ្ជាក់ថា អង្គភាពព័ត៌មានអនឡាញជាភាសាខ្មែរ គឺសហព័ន្ធអ្នកសារព័ត៌មានកម្ពុជា-អាស៊ានរស្មីកំពង់ចាមនិងដំណឹងក្នុងស្រុក បានប្រព្រឹត្តកំហុសខាងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានយ៉ាងធ្ងន់ធ្ងរនិងមិនព្រមអនុវត្តតាមការណែនាំរបស់ក្រសួងជាអាណាព្យាបាល។*

*លោក ជា លីហ៊ាង ប្រធាន និងជាចាងហ្វាងរបស់សហព័ន្ធអ្នកសារព័ត៌មានកម្ពុជា-អាស៊ាន បានសម្តែងការខកចិត្ត ដែលក្រសួងព័ត៌មានបានដកអាជ្ញាបណ្ណអង្គភាពសារព័ត៌មានរបស់លោក ដោ យគ្មានការពន្យល់ច្បាស់លាស់ទាល់តែសោះ។*

លោកលីហៀងបានប្រាប់ខេមបូចាថា“យើងសោកស្ដាយចំពោះបញ្ហានេះ។សូមបង្ហាញបញ្ហាឲ្យច្បាស់មកថា យើងបានធ្វើកំហុសអ្វី។

លោក លី ហ៊ាង បាននិយាយថា ក្រសួងព័ត៌មានបានកោះហៅគាត់មកប្រជុំកាលពីខែកុម្ភៈ ហើយបានស្នើឱ្យគាត់ដកអត្ថបទដែលចោទថាមន្ត្រីរដ្ឋាភិបាលបានក្លែងបន្លំឯកសារយកដីធ្លី និងករណីមួយទៀតពាក់ព័ន្ធនឹងការជំរិតទារប្រាក់ពីគ្រួសារក្រីក្រ។

របាយការណ៍មួយដែលបានចុះផ្សាយក្នុងអង្គភាពសារព័ត៌មានទាំងបី បានចោទថា សមាជិកសភាជាន់ខ្ពស់នៃគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាច គឺលោក ស ចំរ៉ុង អតីតអភិបាលរងខេត្តបន្ទាយមានជ័យ បានក្លែងបន្លំឯកសារ ដើម្បីទទួលបានដីជាង ៦០ ហិកតា នៅខេត្តបន្ទាយមានជ័យ។

លោក លី ហ៊ាង បាននិយាយថា លោក សរ ចំរ៉ុង បានប្ដឹងទៅក្រសួងព័ត៌មានអំពីការចុះផ្សាយនេះ។

លោក ចំរ៉ុង ជាប្រធានគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង និងអង្កេតនៃរដ្ឋសភា។ កាលពីខែកុម្ភៈ ឆ្នាំ ២០២០ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ បានដឹកនាំគណៈប្រតិភូទៅគោរពវិញ្ញាណក្ខន្ធក្នុងពិធីបុណ្យសពម្ដាយរបស់ ចំរ៉ុង។

ខេមបូចា មិនអាចទាក់ទងលោក ចំរ៉ុង ដើម្បីសុំការបំភ្លឺបានទេ។

លោក លី ហ៊ាង និយាយថា ក្រសួងព័ត៌មានបានអះអាងថា អត្ថបទនេះបានធ្វើឲ្យខូចកិត្តិយសមន្ត្រីរដ្ឋសភា។ លោក លី ហ៊ាង បានបន្តថា “ខ្ញុំបានឆ្លើយថា ខ្ញុំមិនអាចលុបព័ត៌មាននោះចេញបានទេ ព្រោះវាជាព័ត៌មានពិតជាពិសេស ជាការកុហកចំពោះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន”។

អត្ថបទមួយទៀតចុះផ្សាយក្នុងអង្គភាពសារព័ត៌មានទាំងបីបានរាយការណ៍ថា ព្រះរាជអាជ្ញារងខេត្តតាកែវម្នាក់បានរឹបអូសទ្រព្យសម្បត្តិពីអ្នកភូមិបីគ្រួសារដែលបានទិញពីខេត្តរតនគិរី ហើយទាមទារឱ្យអ្នកភូមិបង់ប្រាក់ឱ្យព្រះរាជអាជ្ញារូបនោះដើម្បីបានទ្រព្យនោះមកវិញ។

លោក ជា សារ៉េន ចាងហ្វាងដំណឹងក្នុងស្រុក បានចុះផ្សាយអត្ថបទដូចគ្នានេះ រួមមានទាំងវីដេអូ ដែលមានអ្នកចូលមើលជាង១៦៩,០០០ដងនៅលើហ្វេសប៊ុក។ លោកនិយាយថា ក្រសួងព័ត៌មានបានស្នើឲ្យលោកដកអត្ថបទចេញ តែលោកបដិសេធ។

លោកបន្តថា៖ «យើងបានចុះផ្សាយព័ត៌មានពិតរបស់អ្នកភូមិ ដែលអាចធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកដទៃ»។

អ្នកនាំពាក្យក្រសួងព័ត៌មាន លោក មាស សោភ័ណ្ឌ បានបដិសេធថា ក្រសួងមិនបានស្នើឲ្យអ្នកសារព័ត៌មានដកអត្ថបទចេញនោះទេ។ លោកបានមានប្រសាសន៍ថា អង្គភាពសារព័ត៌មានបានផ្សាយ "ព័ត៌មានមិនពិត" ហើយបានចោទមន្ត្រីថាបានអនុវត្តតាមការបញ្ជាពីភាគីខាងក្រៅ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន។

បន្ទាប់ពីលុបអាជ្ញាបណ្ណ សារព័ត៌មានដំណឹងក្នុងស្រុក បានបង្ហោះសារលាអ្នកតាមដានព័ត៌មានតាមទំព័រហ្វេសប៊ុករបស់ខ្លួន។

ដំណឹងក្នុងស្រុកបានសរសេរថា«សូមលាបងប្អូនអាជីពអ្នកសារព័ត៌មានទូទាំងព្រះរាជាណាចក្រកម្ពុជាដែលកំពុងស្រឡាញ់វិស័យសារព័ត៌មាន សូមឱ្យមានសុខភាពល្អ នឹងជួយបន្តការផ្សព្វផ្សាយព័ត៌មានពិតជូនសង្គមជាតិ ដើម្បីមាតុភូមិ"។

ប្រភព៖ https://bit.ly/40nhlpl

**ប្រភេទនៃការយាយី៖ ការបិទ ឬផ្អាកដំណើរការប្រព័ន្ធផ្សព្វផ្សាយដោយអាជ្ញាធរ**

## ២. លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បិទប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ VOD

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា រដ្ឋាភិបាលបានលុបចោលអាជ្ញាបណ្ណផ្សាយព័ត៌មាន VOD តាមហ្វេសប៊ុកកាលពីខែកុម្ភៈ បន្ទាប់ពីលោកបានទាមទារការសុំទោសចំពោះអត្ថបទដែលលោកអះអាងថាមិនត្រឹមត្រូវ។

លោកនាយរដ្ឋមន្ត្រីបានសរសេរនៅលើទំព័រហ្វេសប៊ុករបស់លោកថា "ខ្ញុំបានសម្រេចចិត្តបញ្ចប់បញ្ហានេះ ដោយឱ្យក្រសួងព័ត៌មានលុបចោលអាជ្ញាបណ្ណ VOD ចាប់ពីពេលនេះទៅ និងត្រូវបញ្ចប់ការផ្សាយត្រឹមម៉ោង ១០ ព្រឹក ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០២៣ជាកំហិត។ យើងបិទការផ្សាយគ្រប់ទម្រង់"។

ពីរថ្ងៃមុនដកអាជ្ញាបណ្ណ លោក ហ៊ុន សែន បានបញ្ជាឱ្យសារព័ត៌មាន VOD សុំទោស និងដកចេញនូវអត្ថបទជាភាសាខ្មែរ ដែលបានចុះផ្សាយកាលពីថ្ងៃទី៩ ខែកុម្ភៈ។ អត្ថបទបានរាយការណ៍ថា កូនប្រុសរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺលោក ហ៊ុន ម៉ាណែត បានចុះហត្ថលេខាជំនួសឪពុកលើការផ្តល់ជំនួយចំនួន ១០ ម៉ឺនដុល្លារដល់ប្រទេសតួកគីដែលរងគ្រោះដោយការរញ្ជួយដី។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាល ត្រូវបានដកស្រង់សំដីនៅក្នុងអត្ថបទជាភាសាខ្មែរថា "វាមិនខុសទេ ដែលលោក ហ៊ុន ម៉ាណែត ដើរតួនាទីជំនួសឪពុកក្នុងការផ្តល់ជំនួយដល់ប្រទេសតួកគីនោះ"។

ប៉ុន្តែលោក ហ៊ុន ម៉ាណែត ដែលជាបេក្ខភាពនាយករដ្ឋមន្ត្រីរបស់គណបក្សប្រជាជនកម្ពុជានៅពេលឪពុករបស់លោកចូលនិវត្តន៍នោះ បានបដិសេធរឿងនេះ ដោយលោកបានបង្ហោះសារតាមបណ្តាញសង្គមជាបន្តបន្ទាប់ថា លោកមិនបានចុះហត្ថលេខាលើឯកសារនោះទេ។ លោក ហ៊ុន ម៉ាណែត បានទាមទារឱ្យមានការកែតម្រូវអត្ថបទជាបន្ទាន់ ហើយក៏ឱ្យវីអូឌី ផ្តល់ភស្តុតាងនៃការចុះហត្ថលេខាលើឯកសារផ្តល់ជំនួយនេះដែរ។

កាលពីថ្ងៃទី១១ ខែកុម្ភៈ លោក ហ៊ុន សែន បានបង្ហោះសារនៅលើទំព័រហ្វេសប៊ុករបស់លោកដោយទាមទារឲ្យ VOD ចេញលិខិតសុំទោសជាសាធារណៈចំពោះរដ្ឋាភិបាល និងកូនប្រុសរបស់លោកក្នុងរយៈពេល ៧២ ម៉ោង បើមិនដូច្នេះទេ VODប្រឈមមុខនឹងការលុបចោលអាជ្ញាបណ្ណសារព័ត៌មាន។ ប៉ុន្តែក្រោយមកលោកបានបន្ថយរយៈពេលនៃឱសានវាទ មកនៅត្រឹមម៉ោង ១០ ព្រឹកថ្ងៃទី ១៣ ខែកុម្ភៈ។

បុគ្គលិកមកពីមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ជាអង្គការមិនមែនរដ្ឋាភិបាលគ្រប់គ្រងលើការផ្សព្វផ្សាយព័ត៌មាន VOD បានជួបជាមួយក្រសួងព័ត៌មាននៅព្រឹកថ្ងៃអាទិត្យទី១២ កុម្ភៈ ប៉ុន្តែស្ថានការណ៍មិនអាចបានដោះស្រាយទេ។

បន្ទាប់ពីការប្រាទចោលពីលោក ហ៊ុន ម៉ាណែត សារព័ត៌មាន VOD ជាភាសាខ្មែរ បានចុះផ្សាយអត្ថបទបន្តមួយដោយបញ្ជាក់ថា លោក ហ៊ុន ម៉ាណែត បានបដិសេធថាមិនបានចុះហត្ថលេខាលើឯកសារនេះទេ ហើយ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ក៏បានផ្ញើលិខិតមួយច្បាប់ទៅលោក ហ៊ុន សែន ព្រឹកថ្ងៃអាទិត្យទី១២ ដោយបញ្ជាក់ថា ខ្លួនមានការសោកស្តាយចំពោះ "ការភ័ន្តច្រឡំ" ដែលបណ្តាលមកពីអត្ថបទនោះ។

នៅម៉ោង៧យប់ ថ្ងៃដដែល លោក ហ៊ុន សែន បានបង្ហោះសារតាមហ្វេសប៊ុករបស់លោក ដោយបញ្ជាឲ្យក្រសួងព័ត៌មានលុបចោលអាជ្ញាបណ្ណVOD។ លោកនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា លោកមិនពេញចិត្តនឹងការឆ្លើយតបរបស់VODចំពោះឱសានវាទរបស់លោក ដោយលោកកត់សម្គាល់ថា សារព័ត៌មាននេះបានបដិសេធការសុំទោស ហើយមិនព្រមប្រើប្រាស់ពាក្យដែលលោកចង់បាន។

*រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ បានបង្ហោះសារនៅលើទំព័រហ្វេសប៊ុករបស់លោកថា គេហទំព័រប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតគួរតែយករឿងនេះជាមេរៀន។*

*លោកបានថ្លែងថា៖ «វាជាមេរៀនមួយសម្រាប់ស្ថាប័នសារព័ត៌មានផ្សេងទៀត។ ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយដែលមិនព្រមផ្សព្វការបំភ្លឺ [ពួកគេ] ប្រឈមនឹងការលុបចោលអាជ្ញាបណ្ណរបស់ពួកគេ»។*

*ក្រុមអ្នកអត្ថាធិប្បាយសង្គមបានសម្តែងការសោកស្តាយតាមបណ្តាញសង្គមចំពោះការបាត់បង់ VOD ហើយបានកត់សម្គាល់ថាពេលវេលានៃការបិទនេះគឺកើតឡើងមុនការបោះឆ្នោតជាតិ នៅខែកក្កដា និងភ្លាមៗបន្ទាប់ពីមេដឹកនាំជាន់ខ្ពស់មកពីគណបក្សភ្លើងទៀនប្រឈមមុខនឹងបណ្តឹង ការចាប់ខ្លួន និងការបំភិតបំភ័យ។*

*អ្នកយកព័ត៌មានជាន់ខ្ពស់VOD លោកម៉មមុនីរតន៍បាននិយាយថាលោកមានការខកចិត្តជាខ្លាំងហើយសង្ឃឹមថាដំណោះស្រាយនៅតែអាចមាន។*

*លោកនិយាយថា៖ «ធម្មតាតួនាទីរបស់អ្នកសារព័ត៌មាន ពេលគេឮព័ត៌មានអ្វី គេរាយការណ៍ជាសាធារណៈ។ យើងមិនមានចេតនាអាក្រក់ចំពោះអ្នកណាម្នាក់ទេ។ វាគ្រាន់តែជាការផ្តល់ព័ត៌មានដល់សាធារណជនប៉ុណ្ណោះ» ។*

*ប្រភព៖* https://cambojanews.com/prime-minister-shuts-down-independent-media-vod/

## ប្រភេទនៃការយាយី៖ ការបិទ ឬផ្អាកដំណើរការប្រព័ន្ធផ្សព្វផ្សាយដោយអាជ្ញាធរ

## ៣. ក្រោយការបិទវីអូឌី មានការបង្ករករឿងចំពោះអ្នកសារព័ត៌មាន

*បន្ទាប់ពីការបិទវីអូឌី ដែលបញ្ជាដោយរដ្ឋាភិបាល អង្គភាពសារព័ត៌មាននេះក៏ក្លាយជាកម្មវត្ថុនៃរូបភាពវាយប្រហារមិនសមរម្យតាមប្រព័ន្ធបណ្តាញសង្គម ហើយអ្នកយកព័ត៌មានរបស់អង្គភាពនេះប្រឈមនឹងការវាយប្រហារផ្ទាល់ខ្លួនតាមអ៊ីនធឺណិត និងតាមប្រព័ន្ធផ្សព្វផ្សាយដែលគាំទ្ររដ្ឋាភិបាល។*

*ស្ត្រីអ្នកយកព័ត៌មានវីអូឌី ដែលសរសេរអត្ថបទនោះធ្វើឲ្យលោក ហ៊ុន ម៉ាណែត និង ហ៊ុន សែន ខឹងសម្បារ ហើយក៏ចាប់ផ្តើមរងនូវការជេរប្រមាថឥតសំចៃ និងការបៀតបៀនផ្លូវភេទតាមបណ្តាញសង្គមផងដែរ។*

*លោក ផៃង វណ្ណៈ អ្នកលេងហ្វេសប៊ុកគាំទ្ររដ្ឋាភិបាលមួយរូប និងជាអតីតមន្ត្រីយោធា បានសរសេរជាភាសាខ្មែរនៅលើទំព័រហ្វេសប៊ុករបស់ខ្លួនថា "ជាក្មេងស្រី តែចរិកព្រៃផ្សៃ ចរិកថោកទាប ដូចនាងអាណាយកធ្វើប្រពន្ធងាប់ហើយ"។*

*ក្រុមអង្គការសង្គមស៊ីវិលជាង ៤០ បានចេញសេចក្តីថ្លែងការណ៍រួមថ្កោលទោសការប្រមាថ និង បៀតបៀនផ្លូវភេទលើស្ត្រីអ្នកយកព័ត៌មានវីអូឌី នៅលើបណ្តាញទំនាក់ទំនងសង្គម។*

*លិខិតនេះផ្ញើជូនរដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដោយជំរុញឱ្យក្រសួងទាំងនេះចាត់វិធានការលើលោក ផៃង វណ្ណៈ។*

*លោក ហ៊ុន សែន ស្តីបន្ទោសអង្គការសង្គមស៊ីវិលជុំវិញលិខិតនេះ។ លោក ហ៊ុន សែន បានថ្លែងក្នុងពិធីចែកសញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញកាលពីនៅថ្ងៃទី២០ខែកុម្ភៈថា៖«អង្គការក្រៅរដ្ឋាភិបាលទាំងនេះត្រូវបានបង្កើតឡើងដើម្បីប្រឆាំងរដ្ឋាភិបាល និងមិនបានធ្វើការងារដើម្បីការពារស្ត្រីទេ»។*

*លោកបានបន្ថែមថា "បើចាំបាច់ត្រូវធ្វើសវនកម្ម [អង្គការមិនមែនរដ្ឋាភិបាល] ដើម្បីរកឱ្យឃើញថាតើលុយបានមកពីណា។ យើងមានសិទ្ធិធ្វើដូច្នេះ ហើយក្រសួងមហាផ្ទៃ ឬអង្គភាពប្រឆាំងអំពើពុករលួយអាចស៊ើបអង្កេតបាន"។*

*ក្រសួងកិច្ចការនារីបានឆ្លើយតបនឹងសេចក្តីថ្លែងការណ៍មួយដែលជំរុញឲ្យអង្គការសង្គមស៊ីវិលរក្សាអព្យាក្រឹតភាព និងមិនត្រូវបម្រើផលប្រយោជន៍នយោបាយណាមួយ។*

*សេចក្តីថ្លែងការណ៍បានសរសេរថា "ក្រសួងកិច្ចការនារីសូមអំពាវនាវដល់អង្គការសង្គមស៊ីវិលប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ និងបង្ហាញនូវអព្យាក្រឹតភាពក្នុងការអនុវត្តការងាររបស់ខ្លួនឱ្យបានម៉ឺងម៉ាត់ ចៀសវាងការប្រើប្រាស់ស្តង់ដាពីរ ដែលមានភាពលម្អៀង ដើម្បីតែផលប្រយោជន៍នយោបាយរបស់ខ្លួន។*

លោកស្រី ជឹម ចាន់នាង អគ្គលេខាធិការនៃគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាស្តីពីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍នេះ។ លោកស្រីបានថ្លែងថា គោលបំណងរបស់អង្គការក្រៅរដ្ឋាភិបាល ដែលចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍នេះមិនមែនជារឿងនយោបាយទេ។

លោកស្រីនិយាយថាការថ្កោលទោសលើការយាយីមកលើស្ត្រីអ្នកសារព័ត៌មានវីអូឌី គឺគ្រាន់តែចង់លើកកម្ពស់ការការពារស្ត្រីឲ្យកាន់តែខ្លាំងប៉ុណ្ណោះ។

លោកស្រី ចាន់នាង បាននិយាយថា៖ «យើងមិនកាន់ជើងខាងណាទេ ប៉ុន្តែការពិត គឺថាក្មេងស្រី ដែលរាយការណ៍ព័ត៌មាននេះរងការប្រមាថ ហើយវាជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ។ វាបំផ្លាញកេរ្តិ៍ឈ្មោះរបស់នាង ជាពិសេសប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់នាង"។

បុគ្គលិកវីអូឌី ផ្សេងទៀតក៏បានរងការវាយប្រហារតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងតាមអង្គភាពព័ត៌មានដែលគាំទ្ររដ្ឋាភិបាលផងដែរ។

នៅថ្ងៃដែលអាជ្ញាបណ្ណរបស់វីអូឌី ត្រូវបានលុបចោលនៅថ្ងៃទី១៣ ខែកុម្ភៈ មានអ្នកប្រើប្រាស់ Twitter ជាច្រើននាក់ ដែលហាក់ដូចជាគណនីក្លែងក្លាយបានចាប់ផ្តើមបង្ហោះរូបថ្លុក និងសារដែលសរសេរដូចគ្នាបេះបិទ ហើយអបអរសាទរការបិទវីអូឌី ជាមួយនឹង hashtag #VODshithead ។

គណនី Twitter បានចែករំលែករូបថ្លុកដែលចាត់ទុកវីអូឌី ជាឧបករណ៍របស់ភ្នាក់ងារបរទេសដូចជា "ស្ថានទូតបរទេស" និង អង្គការក្រៅរដ្ឋាភិបាល"។

នៅក្នុងរូបថ្លុកមួយ ដែលមានសញ្ញាអសុរោះ មានរូបមនុស្សស្រដៀងនឹងជនជាតិអាមេរិក ពាក់មួកវែងមានសញ្ញាវីអូឌី មានសញ្ញាវង្វង់ភ្ជាប់នឹងអក្សរថា "អ្នកត្រូវតែប្រកាន់ខ្ជាប់នូវយុទ្ធសាស្ត្រដែលខ្ញុំបានបង្កើតឡើង" ហើយគូសកម្ពុជាដោយមានសរសេរអក្សរថា "សិទ្ធិមនុស្ស និង ប្រជាធិបតេយ្យ"។

អ្នកកាសែតស្បែកសមួយក្រុមឈរមើល ហើយម្នាក់និយាយថា "យើងម្នាក់ៗត្រូវតែធ្វើតាមការណែនាំរបស់ចៅហ្វាយរបស់យើងទាក់ទងនឹងរបាយការណ៍ក្លែងក្លាយ។ចៅហ្វាយយើងឲ្យលុយយើងហើយការពារយើង»។

ការវាយប្រហារមកលើអ្នកយកព័ត៌មានវីអូឌី បានធ្វើឡើងដោយអង្គភាពព័ត៌មានដែលគាំទ្ររដ្ឋាភិបាល។ បន្ទាប់ពីមានការចុះផ្សាយរបស់សារព័ត៌មាន BBC ទាក់ទងនឹងអ្នកយកព័ត៌មានវីអូឌីមួយរូប គឺលោក ម៉ិច ដារ៉ា ដែលមានចំណងជើងថា «កម្ពុជា៖ បន្ទប់ព័ត៌មានដែលខ្ញុំធ្វើការត្រូវបំបិទសំឡេង»នោះ កាសែតភ្នំពេញប៉ុស្តិ៍ ដែលលោក ដារ៉ាធ្លាប់ធ្វើការជាបុគ្គលិក បានព្យាយាមវាយប្រហារលោក ដារ៉ា តាមរយៈធ្វើឲ្យបាត់បង់ទំនុកចិត្តមកលើលោក ដារ៉ា ដោយព្យាយាមបង្ហាញថាលោក ដារ៉ា មានបញ្ហាខាងផ្លូវចិត្ត។

នៅក្នុងបទវិចារណកថាចុះនៅថ្ងៃទី១៧ខែកុម្ភៈដែលមានចំណងជើងថា"ប៉ុស្តិ៍:"ត្រូវបិទ"និង"បំបិទសំឡេង"? កាសែតភ្នំពេញប៉ុស្តិ៍បានជំទាស់នឹងសំដីរបស់លោក ម៉ិច ដារ៉ា ថា ខ្លួនបាន"ចាកចេញដោយសារតែកាសែតនេះបានផ្លាស់ប្តូរម្ចាស់ទៅជាក្រុមហ៊ុន PR ដែលមានទំនាក់ទំនងជិតស្និទ្ធនឹងរដ្ឋាភិបាលក្នុងឆ្នាំ២០១៨។

ប៉ុន្តែវិចារណកថាដែលគ្មានឈ្មោះអ្នកសរសេរនោះក៏បានបញ្ចូលផ្នែកមួយដែលនិយាយពី"អំពីបុគ្គលិកលក្ខណៈរបស់ដារ៉ា" ដែលចាត់ទុកដារ៉ាថា "មនុស្សកំសាក" "ប៉ះទង្គិចផ្នែកផ្លូវចិត្ត" ហើយមាន "គុណវិបត្តិបុគ្គលិកលក្ខណៈ។

ដារ៉ាបដិសេធមិនធ្វើអត្ថាធិប្បាយទេ។

លោក J. Daniel Sims នាយកអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិប្រឆាំងនឹងការជួញដូរមនុស្សនៅកម្ពុជា បានកត់សម្គាល់នៅក្នុងបណ្តាញ Twitter ថា លោក ម៉ិច ដារ៉ា គឺជាអ្នកយកព័ត៌មានម្នាក់ក្នុងចំណោមអ្នកយកព័ត៌មានវីរឱឡារីទាំងអស់ ដែលបានលាតត្រដាងជាបន្តបន្ទាប់នូវរបាយការណ៍ជួញដូរមនុស្ស និងការបោកប្រាស់នៅកម្ពុជា។

លោក Sims បាននិយាយអំពីការវាយប្រហាររបស់កាសែតភ្នំពេញប៉ុស្តិ៍មកលើលោក ដារ៉ាថា "នេះគឺជាទម្រង់នៃយន្តការដ៏អាក្រក់ និងគ្រោះថ្នាក់បំផុត ព្រោះវាកាត់បន្ថយយ៉ាងមានប្រសិទ្ធភាពទៅលើវិធានការនៃការប្រើអំពើហិង្សាដែលអាចកើតមានលើគាត់[ដារ៉ា]"។ ក្នុងបរិបទដូចនេះ ហានិភ័យនៃលទ្ធផលដ៏គួរឱ្យរន្ធត់បែបនេះ គឺគ្មានអ្វីក្រៅតែពីប្រើទ្រឹស្តីនោះទេ។"

ប្រភព៖ https://cambojanews.com/after-vod-shutdown-hostility-against-reporters/

**ប្រភេទនៃការបៀតបៀន៖ ការបៀតបៀនផ្លូវភេទតាមអ៊ីនធឺណិត និងការគំរាមកំហែងតាមអ៊ីនធឺណិត**

## ៤. អ្នកសារព័ត៌មានអនឡាញត្រូវបានចាប់ខ្លួនបន្ទាប់ពីថតរូបការរត់ពន្ធបារី

*នៅថ្ងៃទី២៨ ខែមករា ឆ្នាំ ២០២៣ លោក ស៊ិន សូរីដា អ្នកសារព័ត៌មានអនឡាញ Sangkom Pachabon ត្រូវបាន នគរបាលមួយក្រុមចាប់ខ្លួន បន្ទាប់ពីគាត់បានរាយការណ៍ព័ត៌មានអំពីការរត់ពន្ធបារីនៅក្នុងខេត្តកណ្តាល។*

*តាមអ្នកយកព័ត៌មានវ័យ៣០ឆ្នាំរូបនេះ គាត់បានឃើញបុរសរត់ពន្ធបារីឆ្លងកាត់ព្រំដែនកម្ពុជាវៀតណាមតាម ច្រកព្រំដែនក្អមសំណរដោយចៃដន្យ ពេលគាត់ទៅលេងសាច់ញាតិនៅទីនោះ។*

*លោកបានប្រាប់ ខេមបូចា តាមរយៈបទសម្ភាសន៍តាមទូរស័ព្ទថា លោកបានថតរូបភាពសកម្មភាពរត់ពន្ធនេះ ហើយបានទៅប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ក្អមសំណរ ដើម្បីរាយការណ៍ករណីនេះប៉ុន្តែនគរបាលបានបង្វែរ គាត់ឲ្យទៅរាយការណ៍ទៅមេរបស់ពួកគេវិញ។សូរីដាបាននិយាយថាគាត់មិនបានធ្វើតាមការណែនាំទេ ហើយ ក៏បានចាកចេញពីប៉ុស្តិ៍នគរបាល។*

*នៅពេលត្រឡប់មកពីប៉ុស្តិ៍នគរបាល គាត់បាននិយាយថា នគរបាលជាង១០នាក់បានជិះម៉ូតូតាមគាត់ ហើយបញ្ជាឱ្យឈប់។ សូរីដា ត្រូវបានគេនាំទៅប៉ុស្តិ៍នគរបាល ហើយត្រូវបានចោទថា "រាយការណ៍ដោយ គ្មានលិខិតបេសកកម្ម និងមិនបានផ្តល់ដំណឹងដល់នគរបាល មុនពេលបំពេញការងារជាសារព័ត៌មាន"។*

*សូរីដា បានប្រាប់ ខេមបូចា ថាគាត់ត្រូវបង្ខំចិត្តទទួលស្គាល់ជាលាយលក្ខណ៍អក្សរថា គាត់ខុស ហើយបានលុប រូបភាពដែលគាត់បានថតជាថ្នូរនឹងការដោះលែង។*

*ប្រភព៖* https://bit.ly/3RulMva

**ប្រភេទនៃការយាយី៖**
**ការគំរាមកំហែងដោយពាក្យសំដី**

## ៥. អ្នកសារព័ត៌មានអនឡាញ រងការយាយីផ្នែករាងកាយដោយម្ចាស់អាជីវកម្មបូមខ្សាច់

*លោក ស៊ិន សំណាង និពន្ធនាយកសារព័ត៌មាន BTN និយាយថា លោកត្រូវបានម្ចាស់អាជីវកម្មបូមខ្សាច់ លោក ឡាយ រ៉ា កញ្ឆក់យកបណ្ណសារព័ត៌មានរបស់លោក ខណៈពេលដែលលោកកំពុងរាយការណ៍ព័ត៌មាន ពីផលប៉ះពាល់នៃការបូមខ្សាច់លប់វាលស្រែកាលពីថ្ងៃទី ២៦ ខែមករា នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។*

*លោក សំណាងនិយាយថា គាត់ក៏ត្រូវគេរុញឲ្យធ្លាក់ប្រឡាយទឹក បណ្តាលឱ្យខូចទូរស័ព្ទដៃ។*

*លោក សំណាង ប្រាប់ ខេមបូចា ថា ករណីនេះត្រូវបានដោះស្រាយរួច បន្ទាប់ពីលោកយល់ព្រមទទួលយក សំណងពីលោក ឡាយ រ៉ា នៅប៉ុស្តិ៍នគរបាល។*

*ប្រភព៖* https://bit.ly/3Rgyj5r

**ប្រភេទនៃការយាយី៖**
**ការវាយប្រហារលើឧបករណ៍ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន / ការវាយប្រហារលើរាងកាយ**

## ៦. អ្នកសារព័ត៌មានអនឡាញពីរនាក់ត្រូវបានអ្នកលេងល្បែងម្នាក់កញ្ឆក់យកទូរស័ព្ទ

*លោក អ៊ុន ចន្ថា អ្នកយកព័ត៌មានអនឡាញ និងជាចាងហ្វាងសារព័ត៌មានរស្មីក្រុងតាខ្មៅ បាននិយាយថា លោកត្រូវបានជនមិនស្គាល់មុខជាអ្នកលេងល្បែងជល់មាន់ម្នាក់កញ្ឆក់យកទូរស័ព្ទដៃទៅបោកចោល កាលពីថ្ងៃទី២៣ ខែមករា ខណៈលោកកំពុងថតសង្វៀនជល់មាន់នៅភ្នំពេញ។ លោក ស៊ុន ក្វាន់ចា អ្នកយកព័ត៌មានម្នាក់ទៀតពីសារព័ត៌មានភ្នំពេញចិត្ត ដែលទៅទីនោះដែរ បានប្រាប់ ខេមបូចា ថា អ្នកជល់មាន់ក៏បានព្យាយាមកញ្ឆក់យកទូរស័ព្ទពីលោកដែរ ប៉ុន្តែកញ្ឆក់យកមិនបាន។*

*អ្នកសារព័ត៌មានទាំងពីរបានដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលសង្កាត់ព្រែកប្រា ក្រោយពីមានហេតុការណ៍កើតឡើង។*

*ប្រភព៖* https://bit.ly/3DbdUZH

**ប្រភេទនៃការយាយី៖**
**ការវាយប្រហារលើឧបករណ៍**
**និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន/**
**ទ្រព្យសម្បត្តិផ្សេងទៀត**
**នៃអង្គភាពព័ត៌មាន**

## ៧. អាជ្ញាបណ្ណគេហទំព័រត្រូវបានដកហូតបន្ទាប់ពី 'ការបំពានក្រមសីលធម៌យ៉ាងធ្ងន់ធ្ងរ'

*ក្រសួងព័ត៌មាន បានដកហូតអាជ្ញាបណ្ណរបស់គេហទំព័រព័ត៌មាន* Khmer Cover TV (KCTV) *នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ បន្ទាប់ពីរកឃើញថា អង្គភាពសារព័ត៌មានបានប្រព្រឹត្តកំហុសខាងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានយ៉ាងធ្ងន់ធ្ងរ។*

*យោងតាមសេចក្តីថ្លែងការណ៍របស់ក្រសួងព័ត៌មានចុះហត្ថលេខាដោយរដ្ឋមន្ត្រី អង្គភាពសារព័ត៌មាន* KCTV *បានប្រព្រឹត្តកំហុសខាងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានយ៉ាងធ្ងន់ធ្ងរ ហើយបានបដិសេធពីរដងមិនអនុវត្តតាមការណែនាំរបស់ក្រសួង ដែលផ្ទុយនឹងកិច្ចសន្យាអាជីវកម្មដែលសាមីខ្លួនបានតម្កល់ទុកនៅក្រសួងព័ត៌មាន ទោះជាយ៉ាងណា សេចក្តីថ្លែងការណ៍មិនបានលើកឡើងពីករណីជាក់លាក់ណាមួយអំពីការប្រព្រឹត្តកំហុសខាងក្រមសីលធម៌នោះឡើយ។*

*អង្គភាពព័ត៌មានអនឡាញនេះ គឺស្ថិតក្នុងចំណោមអង្គភាពសារព័ត៌មានបីដែលត្រូវក្រសួងព័ត៌មានធ្លាប់លុបចោលអាជ្ញាបណ្ណកាលពីនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ដោយសារ "ការផ្សាយព័ត៌មានដែលបំពានក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន និងកិច្ចសន្យាអាជីវកម្ម"។ ក្រសួងបានកែសម្រួលសេចក្តីសម្រេចរបស់ខ្លួននៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ ដែលអនុញ្ញាតឱ្យអង្គភាពសារព័ត៌មានទាំងបីអាចដំណើរការឡើងវិញបាន។*

*កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ អង្គភាពសារព័ត៌មាន* KCTV *បានចុះផ្សាយអត្ថបទ និងវីដេអូឃ្លីបមួយដែលបង្ហាញពីកម្មករក្រុមហ៊ុន ឡេង ណាវ៉ាត្រា គ្រុប បូមខ្សាច់ចាក់លុបបឹង ដើម្បីសាងសង់ផ្លូវបេតុង ចូលទៅកាន់គម្រោងអភិវឌ្ឍន៍របស់ឧកញ៉ា នៅស្រុកល្វាឯម ខេត្តកណ្តាល។ ការបូមខ្សាច់ចាក់លុបតំបន់ដីសើមនៅជុំវិញរាជធានីភ្នំពេញ បានរងការរិះគន់ជាយូរមកថា បានបង្កឲ្យមានទឹកជំនន់កាន់តែអាក្រក់ទៅៗនៅក្នុង*

*រាជធានី។*

*ក្រុមហ៊ុនហ្គាឡាក់ស៊ីរបស់លោកណារ៉ាត្រាបានផ្ញើលិខិតទាមទារឱ្យអង្គភាពសារព័ត៌មាន* KCTV *ដកឃ្លីបវីដេអូ និងអត្ថបទចេញ ហើយអះអាងថា អង្គភាពសារព័ត៌មានបានបរិហារកេរ្តិ៍។*

KCTV *បានបដិសេធមិនដកអត្ថបទព័ត៌មាននិងវីដេអូចេញពីទំព័រហ្វេសប៊ុករបស់ខ្លួនទេ។ លោក មីន ឃឿន ជាចាងហ្វាង បានប្រាប់ ខេមបូចា ថា អត្ថបទ និងវីដេអូនេះជារឿងពិត ហើយ* KCTV *មានសិទ្ធិផ្សាយព័ត៌មាន។ លោកនិយាយថា លោកមិនបានជំរិតទារប្រាក់ ឬបន្ថុចឈ្មោះលោក ឡេង ណារ៉ាត្រាទេ។*

*ប្រភព៖* https://www.khmertimeskh.com/501223002/websites-license-revoked-after-serious-ethical-violations/

*ប្រភព៖* https://cambojanews.com/journalists-facing-extortion-charges-tycoon-threats-for-sensitive-

**ប្រភេទនៃការយាយី៖ ការបិទ ឬផ្អាកដំណើរការអង្គភាពសារព័ត៌មានដោយអាជ្ញាធរ**

## ៨. អ្នកសារព័ត៌មានពលរដ្ឋម្នាក់ត្រូវបានចាប់ខ្លួន និងបង្ខំឲ្យលុបរូបថត

*អ្នកសារព័ត៌មានពលរដ្ឋឈ្មោះ សួន ញាណ ដែលជាសកម្មជនដីធ្លីនៃសហគមន៍ឡពាង ត្រូវបានចាប់ខ្លួន នៅពេលគាត់កំពុងថតរូបសមាជិកសហគមន៍ឡពាង ប្រមាណ ៥០នាក់ ដែលប្រមូលផ្តុំគ្នាតវ៉ានៅមុខតុលាការខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣។*

*លោក សួន ញាណនិយាយថា គាត់ត្រូវបាននគរបាលខេត្តចំនួន៤នាក់ រុញចូលក្នុងឡាន តាមបញ្ជារបស់ព្រះរាជអាជ្ញា ដោយចោទគាត់ថា បានថតរូបដោយគ្មានការអនុញ្ញាត ហើយក៏បញ្ជូនលោកទៅស្នងការដ្ឋាននគរបាលខេត្ត ហើយគេបញ្ជាឲ្យគាត់លុបរូបថតទាំងអស់ចោល។ លោកបាននិយាយថា នគរបាលបានរឹបអូសទូរស័ព្ទចំនួន ៣ គ្រឿង គឺមួយគ្រឿងពីគាត់ និងពីរគ្រឿងទៀតពីអ្នកតវ៉ា។*

*លោក ញាណ ត្រូវបានដោះលែងប្រហែលពីរម៉ោងក្រោយមក បន្ទាប់ពីគាត់បានលុបរូបថតចេញពីទូរស័ព្ទរបស់គាត់។*

*ប្រភព៖* https://bit.ly/3H4cwZT

**ប្រភេទនៃការយាយី៖**
**ការបំភិតបំភ័យដោយពាក្យសំដី**
**និងការវាយប្រហារលើឧបករណ៍**
**និងរបស់ផ្ទាល់ខ្លួន/ឧបករណ៍**
**អង្គភាពសារព័ត៌មាន**

# ព្រឹត្តិការណ៍បច្ចុប្បន្នភាពសំខាន់ៗអំពីស្ថានភាពអង្គភាពសារព័ត៌មាននៅកម្ពុជា

## I. ស្ថានទូត និងអង្គការសង្គមស៊ីវិលព្រមានថា ការបិទវីអូឌី ធ្វើឲ្យខូចដល់សេរីភាពសារព័ត៌មាន

បន្ទាប់ពីរដ្ឋាភិបាលបានបិទអង្គភាពសារព័ត៌មានឯករាជ្យ គឺសំឡេងប្រជាធិបតេយ្យ (VOD) កាលពីថ្ងៃទី១៣ កុម្ភៈ ក្រុមសង្គមស៊ីវិលរាប់សិបបានរិះគន់ការសម្រេចចិត្តបិទនេះ ហើយស្ថានទូតជាច្រើនក៏បានព្រមានថា ការបាត់បង់សារព័ត៌មានមួយនេះបានធ្វើឲ្យខូចយ៉ាងធ្ងន់ធ្ងរដល់សេរីភាពសារព័ត៌មាននៅកម្ពុជាដែលកំពុងធ្លាក់ចុះ មុនការបោះឆ្នោតជាតិនៅខែកក្កដាខាងមុខ។

បុគ្គលិក និងអ្នកគាំទ្រវីអូឌី បានប្រមូលផ្តុំគ្នាទាំងទឹកភ្នែកនៅការិយាល័យរបស់ខ្លួនក្នុងរាជធានីភ្នំពេញ ខណៈដែលអាជ្ញាធរខណ្ឌ និងមន្ត្រីក្រសួងព័ត៌មានបានប្រគល់លិខិតដកអាជ្ញាបណ្ណសារព័ត៌មានជាផ្លូវការនៅព្រឹកថ្ងៃទី ១៣ កុម្ភៈ។

លោក អ៊ិត សូធឿត នាយកផ្នែកប្រព័ន្ធផ្សព្វផ្សាយនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) ដែលជាអង្គការគ្រប់គ្រងសារព័ត៌មាន វីអូឌី បាននិយាយថា "យើងនឹងនៅស្ងៀមៗ យើងនឹងមិនបន្តការផ្សាយទេ"។

អង្គការសង្គមស៊ីវិលជាង៩០ រួមទាំងខេមបូចា បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍មួយកាលពីថ្ងៃនៅថ្ងៃទី ១៣ ដោយបញ្ជាក់ថា ពួកគេខកចិត្តយ៉ាងខ្លាំងចំពោះការសម្រេចចិត្តបិទវីអូឌី ។ សេចក្តីថ្លែងការណ៍ក៏បានថ្កោលទោសផងដែរ ចំពោះការប្រមាថស្ត្រីតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលសំដៅទៅលើស្ត្រីអ្នកសារព័ត៌មានវីអូឌី ជាអ្នកសរសេរអត្ថបទ ដែលធ្វើឲ្យនាយករដ្ឋមន្ត្រីមានការខឹងសម្បារ។

សេចក្តីថ្លែងការណ៍បានកត់សម្គាល់ថា ការចូលទៅកាន់គេហទំព័រ និងម៉ាស៊ីនមេរបស់វីអូឌី ក៏ត្រូវបានរាំងដោយក្រុមហ៊ុនផ្តល់សេវាចល័ត និងអ៊ីនធឺណិតមួយចំនួនផងដែរ។

គណៈប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា រួមជាមួយនឹងស្ថានទូតអូស្ត្រាលី អាមេរិក អង់គ្លេស បារាំង អាល្លឺម៉ង់ និងស៊ុយអែត បានចេញសេចក្តីថ្លែងការណ៍កាលពីថ្ងៃទី១៣ កុម្ភៈ ដោយសម្តែងការព្រួយបារម្ភអំពីការបិទវីអូឌី។

ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ បាននិយាយកាលពីថា "យើងមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការសម្រេចចិត្តភ្លាមៗក្នុងការដកហូតអាជ្ញាបណ្ណវិទ្យុសំឡេងប្រជាធិបតេយ្យ វីអូឌី "។ យើងជំរុញឲ្យអាជ្ញាធរកម្ពុជាពិនិត្យមើលការសម្រេចនេះឡើងវិញ»។

សហភាពអឺរ៉ុបប្រចាំកម្ពុជាបាននិយាយថា៖ «ការសម្រេចចិត្តនេះប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេរីភាពសារព័ត៌មាន និងពហុបក្ស ដែលមានសារៈសំខាន់សម្រាប់សង្គមបើកចំហ និងសេរី»។ «សិទ្ធិទទួលបានព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិ គឺជាគោលការណ៍ជាមូលដ្ឋាននៃសង្គមប្រជាធិបតេយ្យ និងជាមូលដ្ឋានគ្រឹះសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ សិទ្ធិទាំងនេះមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា ហើយគួរតែទទួលបានការការពារយ៉ាងពេញលេញ»។

លោក Phil Robertson នាយករងផ្នែកអាស៊ីនៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស Human Rights Watch បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍ថា "ការសម្រេចចិត្តមិនច្បាស់លាស់ និងមិនសមហេតុផលនេះ ស្ទើរតែបិទបាំងចេតនាពិតប្រាកដរបស់រដ្ឋាភិបាល ដើម្បីបង្រ្កាបលើសេរីភាពប្រព័ន្ធផ្សព្វផ្សាយបន្តទៀត" ។

លោក Robertson បានបន្ថែមថា៖ «សហគមន៍អន្តរជាតិត្រូវតែភ្ញាក់ពីដំណេកដ៏លង់លក់ក្នុងរឿងកម្ពុជា។ គឺត្រូវតែមានយុទ្ធនាការដាក់សម្ពាធសាធារណៈជាបន្ទាន់ទៅលើលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរដ្ឋាភិបាលរបស់លោក ដើម្បីឲ្យគោរពសិទ្ធិ ឬ គេអាចចាត់ទុកថាជាលទ្ធិប្រជាធិបតេយ្យដែលបរាជ័យ ហើយគេអាចធ្វើដូច្នេះបានតាមរយៈជំនួយ និងពាណិជ្ជកម្ម។

រដ្ឋមន្ត្រីក្រសួងកសិកម្ម លោក ឌិត ទីណា ដែលកាលពីឆ្នាំមុនបានគំរាមប្តឹងអង្គភាពសារព័ត៌មាននេះ ដោយសារអង្គភាពនេះបានរាយការណ៍អំពីការត្អូញត្អែររបស់កសិករនោះ បាននិយាយបញ្ជិតបញ្ជៀងថា វីអូឌី បានទទួលនូវអ្វីដែលខ្លួនសមនឹងទទួល។

លោកបានសរសេរនៅលើ Twitter ថា៖ «យូរមកហើយ យើងបានប្រាប់ពួកគេពីអ្វីដែលត្រូវ និងអ្វីដែលខុស។ តើពួកគេបានរៀនឬទេ? សង្ឃឹមថា ពួកគេបានរៀនលើកនេះ"។

លោកស្រី ចក់ សុភាព នាយិកាប្រតិបត្តិនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបាននិយាយថា "ដរាបណារាជរដ្ឋាភិបាលកម្ពុជា យល់ឃើញថាការបញ្ចេញមតិរិះគន់ថាជាឧក្រិដ្ឋកម្ម នោះសេរីភាពនៃការបញ្ចេញមតិនឹងបន្តកើតមាន ត្រឹមតែជាសេចក្តីប្រាថ្នាប៉ុណ្ណោះក្នុងប្រទេសកម្ពុជា"។

លោក សូជឿត នៃ CCIM បាននិយាយថា អង្គការនៅតែព្យាយាមរកវិធីជួយបុគ្គលិកជាង៤០ នាក់របស់ខ្លួន ហើយនឹងខិតខំបន្តការងារក្នុងកម្រិតលទ្ធភាពណាមួយ។

លោកនិយាយថា "យើងនឹងព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីធ្វើការជាមួយភាគីពាក់ព័ន្ធ ដើម្បីដំណើរការវីអូឌី និងបន្តផ្តល់ព័ត៌មានគួរឱ្យទុកចិត្តដល់ប្រជាជនកម្ពុជា។ ប្រសិនបើវីអូឌី មិនអាចបន្តទៅមុខបានទេ យើងចាត់ទុកថាជាជំហានថយក្រោយសម្រាប់វិស័យសារព័ត៌មាននៅកម្ពុជា»។

ប្រភព៖ https://cambojanews.com/shutdown-of-vod-undermines-press-freedom-embassies-and-civil-society-groups-warn/

## II. អ្នកសារព័ត៌មាន ខេត្តឧត្តរមានជ័យទាំងអស់បញ្ជាឲ្យមកបង្ហាញខ្លួននៅសាលាខេត្ត

*មន្ទីរព័ត៌មានខេត្តឧត្តរមានជ័យ បានបញ្ជាឱ្យអ្នកសារព័ត៌មានក្នុងខេត្តទាំងអស់មកបង្ហាញខ្លួននៅការិយាល័យរបស់ខ្លួនដោយនិយាយថាប្រសិនបើអ្នកសារព័ត៌មានឬអង្គភាពសារព័ត៌មានណាមួយខកខានមិនបានបង្ហាញខ្លួនទេ មន្ទីរនឹងមិនទទួលស្គាល់ការងាររបស់ពួកគេនៅក្នុងខេត្តឡើយ។*

*ក្រុមមន្ត្រីបានចាត់ទុកដំណើរការនេះថាជាទម្លាប់ប៉ុន្តែអ្នកខ្លះបានលើកឡើងពីការព្រួយបារម្ភអំពីការរឹតបន្តឹងកាន់តែខ្លាំងឡើងប្រឆាំងនឹងអ្នកសារព័ត៌មាន។*

*មន្ទីរព័ត៌មានបានចេញសេចក្តីជូនដំណឹងមួយកាលពីខែមុន ដោយបញ្ជាឲ្យចាងហ្វាង និងអ្នកយកព័ត៌មានទាំងអស់របស់គេហទំព័រ ទស្សនាវដ្តី ទូរទស្សន៍ និងកាសែត មកបង្ហាញខ្លួននៅការិយាល័យព័ត៌មានខេត្តចាប់ពីថ្ងៃទី ២ ដល់ថ្ងៃទី៣១ ខែមករា។*

*អ្នកសារព័ត៌មានទាំងអស់ត្រូវយកមកជាមួយនូវអាជ្ញាបណ្ណអង្គភាពសារព័ត៌មា ន ដែលមានសុពលភាពបណ្ណសារព័ត៌មានដែលចេញដោយក្រសួងព័ត៌មាន និងលិខិតណែនាំពីអង្គភាពរបស់ខ្លួន ។*

*សេចក្តីជូនដំណឹងបានបន្តថា គោលបំណង គឺធ្វើឱ្យមានភាពងាយស្រួលក្នុងការកត់ត្រាចំនួនអង្គភាពសារព័ត៌មាននៅក្នុងខេត្ត និងត្រូវរាយការណ៍ជូនអភិបាលខេត្ត។*

*ប្រភព៖* https://bit.ly/3FAJjpw

## III. នាយករដ្ឋមន្ត្រីមានប្រសាសន៍ថា សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងធ្វើរួចរាល់នៅឆ្នាំ២០២៥

*លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងធ្វើរួចរាល់នៅចន្លោះឆ្នាំ២០២៤ និងឆ្នាំ២០២៥ ក្នុងអាណត្តិទី៧របស់រដ្ឋាភិបាល។*

*ថ្ងៃក្នុងពិធីជួបសំណេះសំណាលលើកទី៥ជាមួយអង្គភាពសារព័ត៌មានកាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣ លោក ហ៊ុន សែន មានប្រសាសន៍ថា ដំណើរការសេចក្តីព្រាងច្បាប់នេះត្រូវបានពន្យារពេល ដោយសាររដ្ឋាភិបាលចង់ស្តាប់ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីបញ្ចូលក្នុងច្បាប់បន្ថែមទៀត។*

លោកនាយករដ្ឋមន្ត្រីបានបន្ថែមថា "យើងត្រូវប្រមូលធាតុចូល និងកផ្ទល់ពីគ្រប់ភាគីសម្រាប់សេចក្តីព្រាងច្បាប់នេះ ប៉ុន្តែអង្គការក្រៅរដ្ឋាភិបាលខ្លះចង់ឱ្យរដ្ឋាភិបាលចំណាយពេលច្រើនដើម្បីរៀបចំសេចក្តីព្រាងច្បាប់នេះ"។

ទោះយ៉ាងនេះក្តី អង្គការក្រៅរដ្ឋាភិបាលខ្លះបានជំរុញឲ្យរដ្ឋាភិបាលពន្លឿនដំណើរការសេចក្តីព្រាងច្បាប់នេះ។

រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ បានមានប្រសាសន៍ថា "សេចក្តីព្រាងច្បាប់នេះ កំពុងត្រូវបានពិនិត្យដោយក្រសួងយុត្តិធម៌ បន្ទាប់ពីក្រសួងព័ត៌មានបានបញ្ចប់ការវាយតម្លៃ ដោយមានការសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធផ្សេងទៀត□។

លោកបានបន្តថា ក្រសួងរបស់លោកសហការជាមួយអង្គការយូណេស្កូ និងក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធផ្សេងទៀត នឹងរៀបចំសេចក្តីព្រាងច្បាប់នេះ ឲ្យមានការចូលរួម និងពិគ្រោះយោបល់។

សេចក្តីព្រាងច្បាប់នេះកំណត់សិទ្ធិ និងកាតព្វកិច្ចក្នុងការទទួល និងផ្តល់ព័ត៌មាន ព្រមទាំងគោលការណ៍ វិធាន និងនីតិវិធីក្នុងការទទួលបានព័ត៌មានសម្ងាត់ និងការការពារអ្នកទម្លាយព័ត៌មាន ដើម្បីធានាថា សាធារណជនគ្រប់រូបមានសិទ្ធិទទួលបានព័ត៌មានពីស្ថាប័នសាធារណៈ ស្របតាមរដ្ឋធម្មនុញ្ញកម្ពុជា។

នាយកប្រតិបត្តិនៃសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា លោក ណុប វី បាននិយាយថា សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននេះ បានធ្វើមកយូរពេកហើយ។

លោក វី និយាយថា "ច្បាប់នេះជួយឱ្យប្រព័ន្ធផ្សព្វផ្សាយដំណើរការប្រកបដោយប្រសិទ្ធភាព ជាពិសេសក្នុងការទទួលបានព័ត៌មានពីអ្នកនាំពាក្យ។ លោកបានបន្ថែមថា រហូតមកដល់ពេលនេះ អ្នកសារព័ត៌មានកំពុងជួបការលំបាក ក្នុងការទទួលបានព័ត៌មានពាក់ព័ន្ធពីអ្នកនាំពាក្យ។

លោកបានបន្ថែមថា អ្នកនាំពាក្យក្រសួងនានាគួរតែរួសរាយរាក់ទាក់ និងបើកចិត្តឲ្យទូលាយជាមួយអ្នកសារព័ត៌មាន។

ប្រភព៖ https://cambojanews.com/shutdown-of-vod-undermines-press-freedom-embassies-and-civil-society-groups-warn/

ខេមបូចា
CambojA

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា

*Cambodian Journalists Alliance Association*

## ទំនាក់ទំនង

+855 (0)23 88 23 11

communications@camboja.net

ផ្ទះលេខ១៩ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ